អភិវឌ្ឍន៍អង្គការ សហប្រជាជាតិ ក្នុងការរៀបចំគំរោង អភិវឌ្ឍន៍ ជនជាតិភាគតិច

- យោងតាមការងារចាំបាច់ចំពោះមុខ

**សំរេច**

**ប្រការតែមួយគត់ :** បន្ថែមសមាសភាពក្នុងប្រការ ២ នៃសេចក្ដីសំរេច លេខ ២៣ សសរ. ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៩៥ របស់រាជ រដ្ឋាភិបាល

១១ - លោកតំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាសមាជិក

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៥*

## សេចក្ដីសំរេច លេខ ៨៨ សសរ

## ស្ដីពី

## ការកែសំរួល សេចក្ដីសំរេច លេខ ៧៨ សសរ

## ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- យោងសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល លេខ ៦៥ សសរ ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការលុបនីតិវិធី និង បែបបទចាស់ នៃការនាំឈើចេញ
- យោងសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល លេខ ៧៨ សសរ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការស្រាវជាវ ត្រួតពិនិត្យបាតុភាពឈើមូល ឈើ អារ
- យោងតាមសំណូមពរចាំបាច់ចំពោះមុខ

**សំរេច**

ប្រការ ១ : ត្រូវបានបំពេញបន្ថែមតួនាទី និង ភារកិច្ចរបស់គណៈកម្មការ ក្នុងប្រការ ២ នៃសេចក្តីសំរេច លេខ ៧៨ សសរ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល នូវវាក្យខណ្ឌទី ២ ដែលមានខ្លឹមសារដូចខាងក្រោម ៖

"សហការជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះអន្តរក្រសួងដែលបានកំណត់ដោយ អនុក្រឹត្យ លេខ ០២ អនក្រ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ១៩៩៥ ដើម្បីទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ ទូទាំងព្រះរាជាណាចក្រកម្ពុជា " ។

ប្រការ ២ : ត្រូវបានកែសំរួលខ្លឹមសារប្រការ ៣ នៃសេចក្តីសំរេច លេខ ៧៨ សសរ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ដូចមានខ្លឹមសារខាងក្រោម ៖

" គណៈកម្មការ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម-រុក្ខាប្រមាញ់ និង នេសាទ ជាផ្លូវការ " ។

ប្រការ ៣ : ក្រៅពីការបំពេញបន្ថែមខ្លឹមសារ ក្នុងប្រការ ២ និង កែសំរួលខ្លឹមសារក្នុងប្រការ ៣ ដូចមានចែងខាងលើ សេចក្តីសំរេច លេខ ៧៨ សសរ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល នៅរក្សាទុកជាធរមាន ដដែល ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងកសិកម្ម-រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី

ក្រសួងពាណិជ្ជកម្ម និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងលោក អភិបាលគ្រប់ខេត្ត ក្រុង និង សមាជិកគណៈកម្មការស្រាវជ្រាវ ត្រួតពិនិត្យបាតុភាពឈើមូល-ឈើអារត្រូវទទួលអនុវត្តសេចក្តី សំរេច នេះ តាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខា តទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឬទ្ធិ | ហ៊ុន សែន |

* * *

# III. ការងារបណ្តាក្រសួង

# ទីស្តីការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ប្រកាស

**ប្រកាស លេខ ១០៨១ ឧក. ប្រក ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៥**

ប្រការ ១ ៖ អនុញ្ញាតអោយ អ្នកស្រី ឡឹក សាខាត ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៩៨០៧៣ ស្វ.រ ចុះថ្ងៃទី ០៦ -១១-៩២ អាស័យដ្ឋាន បច្ចុប្បន្ន ភូមិ បុស្ស ឃុំ ក្តោត ស្រុក កំពង់រោទិ៍ ខេត្ត ស្វាយ រៀង បើកដំណើរការ ឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំង ភូមិ ទួលអំពិល ឃុំ ច្រកម្ទេស ស្រុក ស្វាយទាប ខេត្ត ស្វាយរៀង ។

ប្រការ ២ ៖ ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួន ឡើងវិញ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ ដល់សុខភាពប្រជារាស្ត្រ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មាន សំណង ឡើយ ។